ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែកុម្ភៈ ឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

ក្នុងខែកុម្ភៈ ឆ្នាំ២០១៦នេះ ល្បឿនការងារបង្កបង្កើនផលរដូវប្រាំងទទួលបានលទ្ធផលល្អប្រសើរ ជាពិសេសដំណាំស្រូវសម្រេចបាន១១៧,២៨% នៃផែនការ ទិន្នផលជាមធ្យមទទួលបាន៤,៣៤២តោន/ហិកតា តិចជាងឆ្នាំមុនចំនួន៣៧ គ.ក្រ/ហិកតា។ មកទល់ពេលនេះ ខេត្តចំនួន២៤បានបញ្ចប់ការងារដាំដុះស្រូវប្រាំងជាស្ថាពរហើយៗនៅសល់ខេត្តចំនួន១ទៀត(ប៉ៃលិន) និងត្រូវបញ្ចប់ការងារដុះដុះនារយៈពេលដ៏ខ្លីខាងមុខនេះ។ ជាមួយនេះ ប្រជាកសិករបាននឹងកំពុងមមាញឹកដំណើរការច្រូតកាត់ឲ្យទាន់ពេលវេលា ដើម្បីជៀសវាងការបាត់បង់ផលស្រូវក្រោយពេលប្រមូលផលនិងភ្លើងឆេះស្រូវ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានវិធានការបន្តជំរុញការអប់រំ ណែនាំដល់ប្រជាកសិករឲ្យបង្កើនការខិតខំថែទាំដំណាំស្រូវប្រាំង ក៏ដូចជាការថែទាំដំណាំផ្សេងៗទៀតនៅទីកន្លែងដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ក្នុងស្មារតីសន្សំសំចៃទឹក ព្រមទាំងផ្សព្វផ្សាយឲ្យបានទូលំទូលាយបន្ថែមទៀតលើការយកចិត្តទុកដាក់ថែទាំសុខភាពសត្វ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺសត្វដែលអាចកើតឡើងជាយថាហេតុនៅក្នុងរដូវប្រាំងនេះ។ សកម្មភាពគួរកត់សម្គាល់មួយទៀតគឺមន្ត្រីជំនាញរដ្ឋបាល ព្រៃឈើបានសហការជាមួយគណៈកម្មការជាតិចូលរួមទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើតាមស្មារតីនៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ០៩ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦។ ដោយឡែក អធិការដ្ឋានរដ្ឋបាលព្រៃឈើទាំង៤ក្រោមកិច្ចសហការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិទាំង២៥ខេត្ត-រាជធានី បានចុះប្រតិបត្តិការត្រួតពិនិត្យ ទបស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើព្រមៗគ្នាផងដែរ។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំក៏ដូចជាផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្មដែលសម្រេចបានសម្រាប់ខែកុម្ភៈ ឆ្នាំ២០១៦នេះ មានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ លទ្ធផលការងារបង្កបង្កើនផលដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៥-២០១៦

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន៥៣៣.៧៧១ហិកតា តិចជាងឆ្នាំមុនចំនួន៤៧.៥៦៨ហិកតា ក្នុងនោះភ្ជួររាស់ដោយគោ ក្របីចំនួន១៧.៥៨៣ហិកតា ស្មើនឹង៣,២៩% និងគ្រឿងយន្តចំនួន៥១៦.១៨៨ហិកតា ស្មើនឹង៩៦,៧១%
- ផ្ទៃដីសាបសម្រេចបានចំនួន១.១៦៣ហិកតា តិចជាងឆ្នាំមុនចំនួន២.៨៦៩ហិកតា
- ផ្ទៃដីសន្ទូងនិងពង្រោះសម្រេចបានចំនួន៤៨៩.៤៤៨ហិកតា ស្មើនឹង១១៧,២៨% នៃផែនការ៤១៧.៣២៥ហិកតា តិចជាងឆ្នាំមុនចំនួន៦១៧ហិកតា។



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

**១.២ ល្បឿនការងារប្រមូលផលស្រូវរដូវប្រាំងឆ្នាំ២០១៥-២០១៦**

ការងារប្រមូលផលស្រូវប្រាំងសម្រេចបានចំនួន៣៥១.៤៥១ហិកតា ស្មើនឹង៧១,៨១% នៃផ្ទៃដីអនុវត្តចំនួន ៤៨៩.៤៤៨ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន១.៥២៦.០៦៥តោន និងទិន្នផលជាមធ្យមចំនួន៤,៣៤២ តោនក្នុងមួយហិកតា តិចជាងឆ្នាំមុន៣៧គីឡូក្រាមក្នុងមួយហិកតា(ឆ្នាំមុនទទួលបានទិន្នផលគិតជាមធ្យម៤,៣៨០តោន ក្នុងមួយហិកតា)។

**១.៣ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម**

- ផ្ទៃដីដំណាំរួមផ្សំសម្រេចបានចំនួន៧៧.៧៣៧ហិកតា ស្មើនឹង១៨២,០៦%នៃផែនការ៤២.៦៩៨ហិកតា លើសឆ្នាំមុនចំនួន៣.៧៤៥ហិកតា
- ផ្ទៃដីដំណាំឧស្សាហកម្មសម្រេចបានចំនួន១២.៤៨៧ហិកតា ស្មើនឹង៦១,៤២%នៃផែនការ២០.៣៣១ហិកតា តិចជាងឆ្នាំមុនចំនួន១.៤២៩ហិកតា។

**១.៤ ការនាំចេញអង្ករ**

គួរកត់សម្គាល់ថា ការនាំចេញអង្ករកម្ពុជារយៈពេល២ខែដើមឆ្នាំ២០១៦នេះ មានបរិមាណចំនួន៩៥.៩៤៥តោន ដែលមានការកើនឡើងចំនួន២២.៣៤៨តោន(+៣០,៤%) លើសបរិមាណនាំចេញរយៈពេល២ខែដើមឆ្នាំ២០១៥ ដែលមានតែ៧៣.៥៩៧តោន។ ក្នុងនោះបរិមាណនាំចេញក្នុងខែកុម្ភៈនេះមានដល់៥១.៩១២តោន ដែលមានកំណើន១៤.២៣៦តោន (+៣៧,៨%) លើសខែកុម្ភៈ ឆ្នាំ២០១៥ និងបាននាំចេញទៅកាន់ទិសដៅចំនួន៤៤ប្រទេស ក្នុងនោះ ប្រទេសចិនឈរលំដាប់ទី១(២០.៤៣៦តោន) ប្រទេសបារាំងឈរលំដាប់ទី២(១២.៤៥៤តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៣(១០.៧៨៤តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៤(៦.០០២តោន) ប្រទេសនីដឺឡែនឈរលំដាប់ទី៥(៤.៦៣៦តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៦(៤.៥៨៦តោន) ប្រទេសអ៊ីតាលីឈរលំដាប់ទី៧(៣.៥៧៦តោន) ប្រទេសប៊ែលហ្ស៊ិកឈរលំដាប់ទី៨(៣.៤៥២តោន) ប្រទេសឆែកឈរលំដាប់ទី៩(៣.៣៧៩តោន) និងប្រទេសហុងគ្រីឈរលំដាប់ទី១០(៣.២១៥តោន)។

## ២ ផ្នែកកៅស៊ូ

សម្រាប់ខែកុម្ភៈ ឆ្នាំ២០១៦នេះ តម្លៃកៅស៊ូជាមធ្យមគឺ១.០៤២ដុល្លារក្នុងមួយតោន។ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញកៅស៊ូ ដោយគិតតាមរបៀប "ពន្ធគិតតាមឯកតា" លើមុខទំនិញជ័រកៅស៊ូដូចខាងក្រោម៖

- ពុំជាប់អាករនាំចេញ បើតម្លៃគិតអាករនាំចេញទាបជាង១.០០០ដុល្លារអាមេរិកក្នុង១តោន
- ជាប់អាការនាំចេញ ៥០ដុល្លារអាមេរិកក្នុង១តោន បើតម្លៃគិតអាករនាំចេញចាប់ពី១.០០០តែទាបជាង ២.០០០ដុល្លារអាមេរិកក្នុង១តោន
- ជាប់អាករនាំចេញ ១៥០ដុល្លារអាមេរិកក្នុង១តោន បើតម្លៃគិតអាករនាំចេញចាប់ពី២.០០០តែទាបជាង ៣.០០០ដុល្លារអាមេរិកក្នុង១តោន
- ជាប់អាករនាំចេញ ២០០ដុល្លារអាមេរិកក្នុង១តោន បើតម្លៃគិតអាករនាំចេញចាប់ពី៣.០០០តែទាបជាង ៤.០០០ដុល្លារអាមេរិកក្នុង១តោន
- ជាប់អាករនាំចេញ ៣០០ដុល្លារអាមេរិកក្នុង១តោន បើតម្លៃគិតអាករនាំចេញចាប់ពី៤.០០០ដុល្លារអាមេរិកក្នុង១តោនឡើងទៅ។

**២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ**

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហ.ត) | ផលិតផលអនុវត្តបានដល់ខែនេះ (តោន) | បញ្ចេញលក់ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៥០៨ | ៧៥៧ | ១៤៦ | - |
| | សរុប I | ៥០៨ | ៧៥៧ | ១៤៦ | - |

| | | | | | |
|---|---|---|---|---|---|
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ១១.៦១៨ | ១៦.០២៨ | ៣.០៩៩ | ១.៦៨០ |
| ២ | ក្រុមហ៊ុន ស៊ីហ្វ៊ាប់បើលីមីធីត (គុនគីរី) | ៧៩ | ២.៤៩៨ | ១៤ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ៩៩០ | ២.១០១ | ២៦១ | - |
| ៤ | ក្រុមហ៊ុន ឡុង ស្រេង | ២.៣២៨ | ៥.៣៩៤ | ៧៧០ | ១៤៧ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៦៩ | ៨.៦៦១ | ៧១៨ | ២៧៧ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វវិសសស់ (ស្នួល) | ១.៧៤៥ | ៤.៣៦៥ | ៥៣០ | ៣០០ |
| ៧ | ក្រុមហ៊ុនអានម៉ាឌីគ្រុប (ពាមជាំង,រមាសហែក) | ១.៨៨២ | ៣.៣៩០ | ២២៩ | - |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣.៣២៧ | ៥.៩២៤ | ២៨៧ | - |
| ៩ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៣.២៥៦ | ៥.៧៣១ | ៩០៨ | ៤០៦ |
| សរុប II | | ២៨.៤៩៤ | ៥៤.០៩២ | ៦.៨១៦ | ២.៨១០ |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៥.៧៣៥ | ១៨៤.២៥២ | ៦៦២ | ២២៦ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៧៦.៤៩៦ | ១៤៩.៨៥៣ | ១០.១៧៩ | ៣.៤៧២ |
| សរុប III | | ៨២.២៣១ | ៣៣៤.១០៥ | ១០.៨៤១ | ៣.៦៩៨ |
| សរុប I+II+III | | ១១១.២៣៣ | ៣៨៨.៩៥៤ | ១៧.៨០៣ | ៦.៥០៨ |

## ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ចូលរួមរៀបចំស្តីពីការកំណត់បច្ចេកទេសវិទ្យាអាទិភាពជាតិចំនួន១០ ដើម្បីសម្រេចជាគោលដៅអភិវឌ្ឍន៍វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាកម្ពុជា
- ជំរុញអនុវត្តព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល និងគំរូអនុក្រឹត្យបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ប្រជុំពិភាក្សាលើសេចក្តីព្រាងលិខិតគ្រប់គ្រងក្រុមហ៊ុនកៅស៊ូលើដីសម្បទានសេដ្ឋកិច្ច របស់ក្រសួងបរិស្ថាន
- រៀបចំ Report by Conformity Assessment Bodies in Cambodia សម្រាប់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ដែលទាក់ទងមន្ទីរពិសោធន៍ជាតិយថាប្រភេទ
- ចុះបេសកកម្មទៅខេត្តព្រះវិហារ ដើម្បីវាស់ទំហំដើមកូនកៅស៊ូ និងជំរឿនកូនកៅស៊ូងាប់ក្នុងឡូត៍ពិសោធន៍ PV.AA.01
- ធ្វើតេស្តភាគសំណាកយថាប្រភេទចំនួន៣០ភាគសំណាក ដើម្បីបញ្ជាក់គុណភាពកៃឆ្នៃរបស់រោងចក្រក្រុមហ៊ុនឡុង ស្រេង និងកៅស៊ូសន្លឹក
- រៀបចំកម្មវិធីចូលរួមធ្វើតេស្តអន្តរមន្ទីរពិសោធន៍អន្តរជាតិលើកទី១៥ ជាមួយ International Rubber Association (IRA)
- ត្រួតពិនិត្យទិន្នន័យចម្ការពិសោធន៍ IRAE10 ដើម្បីរៀបចំចូលរួមកិច្ចប្រជុំ IRRDB 2016
- វាស់ទំហំដើមចម្ការពិសោធន៍ដីលើកៅស៊ូផ្តល់ផលចម្ការពិសោធន៍ CM-2005, IC2005, CM-2006
- បន្តបណ្តុះបណ្តាលបច្ចេកទេសកៅស៊ូ និងដឹកនាំនិស្សិតសរសេរសារណាបញ្ចប់ការសិក្សាមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មកំពង់ចាម និងសាលាជាតិកសិកម្មព្រែកលៀប។

## ៣ ផ្នែកផលិតកម្មនិងបសុពេទ្យបាល

**៣.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត រៀបចំឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តាខេត្តនិងរាជធានីរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖

- **ការងារកែលម្អពូជ៖** ការកែលម្អពូជកំពុងតែឈានឆ្ពោះទៅមុខជាបណ្តើរ ព្រោះប្រជាកសិករភាគច្រើនកាន់តែមានការយល់ដឹងពីការជ្រើសរើសពូជសត្វដែលផ្តល់ទិន្នផលខ្ពស់ ការលូតលាស់ឆាប់រហ័ស ធន់នឹងជំងឺ និងផ្តល់ប្រាក់ចំណូលគ្រួសារខ្ពស់។

- **ការងារឡជីវឧស្ម័ន៖** ដោយមានការអភិវឌ្ឍផ្នែកចិញ្ចឹមសត្វ ការគ្រប់គ្រងកាកសំណល់ពីសត្វក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់តាមរយៈការអប់រំ ណែនាំ ផ្សព្វផ្សាយ ការអនុវត្តល្អប្រសើរក្នុងការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ ការសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិបាននឹងកំពុងអនុវត្តន៍យ៉ាងសកម្មដែលមកទល់ពេលនេះខេត្តដែលស្ថិតក្រោមការអនុវត្តកម្មវិធីឡជីវឧស្ម័នមាន៖ ខេត្តកំពង់ចាម ស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ កណ្តាល កំពង់ឆ្នាំង កំពត សៀមរាប កំពង់ធំ ត្បូងឃ្មុំ កែប និងពោធិ៍សាត់សម្រេចបាន២១២ឡ និងឡគម្រោងសាធារណរដ្ឋប្រជាមានិតចិនសម្រេចបានចំនួន២៥០ឡ។

- **ចំណីសត្វ៖** បច្ចុប្បន្ននេះមានការវិនិយោគលើការបង្កើតរោងចក្រចំណីសត្វសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក ហើយបានកាត់បន្ថយការនាំចូលចំណីសត្វយ៉ាងច្រើន។ ដោយឡែកប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការផលិត និងមានការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេចយ៉ាងផុសផុល។

- **ការងារដំណាំចំណីសត្វ៖** តាមបណ្តាខេត្តមួយចំនួនបានធ្វើសួនដំណាំចំណីសត្វ ការផ្សព្វផ្សាយអំពីអត្ថ-ប្រយោជន៍នៃការដាំដំណាំចំណីសត្វ ព្រមទាំងផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ ក្រោមកិច្ចសហការជាមួយគម្រោងអន្តរជាតិដូចជា ACIAR និងCIAT ជាដើម។

**៣.២ ការងារបសុពេទ្យបាល**

- លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖

ខេត្ត-រាជធានីចំនួន១៥ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន៣.៩៥៧លើកនៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យនិងបង្ក្រាប ដោយកម្ទេចចោលផលិតផលខូចគុណភាពតាមវិធានបសុពេទ្យសរុបចំនួន៨១,៦គីឡូក្រាម និងផាកពិន័យជាទឹកប្រាក់ចំនួន៥លាន២សែនរៀល ព្រមទាំងបានណែនាំដល់អាជីវករដែលដឹកជញ្ជូនជ្រូករស់ឲ្យប្រតិបត្តិជីវសុវត្ថិភាពពេញលេញ ដើម្បីការពារការឆ្លងរាលដាលនៃជំងឺជ្រូកត្រចៀកខៀវមកពីខេត្តជិតខាង។

- **ការងារសុខភាពសាធារណៈ៖** ចុះត្រួតពិនិត្យទីតាំងស្នើសុំបង្កើតនិងបន្តសុពលភាពសត្តឃាតដ្ឋានប្រភេទ «ក» និង«ខ»តាមបណ្តារាជធានី-ខេត្ត និងចុះត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋានជាប្រចាំឱ្យស្របតាមលក្ខណៈបច្ចេកទេស។

- ស្ថិតិសត្តឃាតដ្ឋានដែលទទួលបានការអនុញ្ញាតនៅទូទាំងប្រទេសសរុបចំនួន១៤២កន្លែង ដូចមានតារាងខាងក្រោម៖

| ល.រ | ឈ្មោះខេត្ត-ក្រុង | ចំនួនសត្តឃាតដ្ឋាន | | ចំនួនសត្វពិឃាដ | | | |
|---|---|---|---|---|---|---|---|
| | | សត្តឃាតដ្ឋានស្របច្បាប់ | ពិឃាតប្រមូលផ្តុំ/ពិឃាតតាមផ្ទះ | គោ (ក្បាល) | ក្របី (ក្បាល) | ជ្រូក (ក្បាល) | មាន់ (ក្បាល) |
| ១ | ភ្នំពេញ | ១១ | | ១៦.២២៦ | ០ | ៣០៧.៣៣៩ | |
| ២ | កណ្តាល | ២២ | | ៤.៣៨៩ | ០ | ៤០.១០២ | ៥៩៩.៧០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | កំពង់ស្ពឺ | ១១ | | ៧.៦៦៩ | ០ | ៣៤.០៨១ | |
| ៤ | ព្រៃវែង | ១២ | | ៣.៣៩០ | ០៩ | ៣៨.១២៤ | |
| ៥ | ស្វាយរៀង | ០៨ | | ១.៥៣៦ | ០ | ១៣.៥៧៦ | |
| ៦ | កំពង់ឆ្នាំង | ១០ | | ៤.០៦០ | ០ | ១៥.០២៩ | |
| ៧ | ពោធិ៍សាត់ | ០៦ | | ២.៨០៥ | ៩០ | ២៥.០៣១ | |
| ៨ | បាត់ដំបង | ១៤ | | ១៣.៨២៤ | ៦៨២ | ៥៨.៣៩៥ | |
| ៩ | បន្ទាយមានជ័យ | ១០ | | ៦.២១៤ | ០ | ៣៥.៨៥៦ | ២៧.៦១២ |
| ១០ | សៀមរាប | ៧ | | ៧.៩៦៤ | ៧០៦ | ៥៧.១១១ | |
| ១១ | កំពង់ធំ | ៦ | | ១.០៩៩ | ៩៣ | ៦.១៦០ | |
| ១២ | ព្រះសីហនុ | ៣ | | ១.៧៣៧ | ៧០ | ៨.៩១២ | |
| ១៣ | កែប | ១ | | ១៥៣ | ០ | ២.៩៨៧ | |
| ១៤ | កំពត | ៥ | | ២.៩១២ | ០៦ | ២៥.៧៨៦ | ១០.៣១០ |
| ១៥ | កោះកុង | ៣ | | ១៤៦ | ១០៩ | ៩.០៩១ | ១៨.៩២៨ |
| ១៦ | ក្រចេះ | ៥ | | ៤.៨៨៥ | ២៦៨ | ៣.១៩៤ | |
| ១៧ | ស្ទឹងត្រែង | ១ | | ១.៤៤២ | ៨៦៣ | ១៥.១៩៧ | |
| ១៨ | រតនគិរី | ៣ | | ២.៩៥៥ | ១.២៧៣ | ១១.២៣៦ | |
| ១៩ | មណ្ឌលគិរី | ២ | | ១.៤៤០ | ០ | ៤.៧៩១ | |
| ២០ | ប៉ៃលិន | ១ | | ៧៩៩ | ០ | ៣.៨៤២ | |
| ២១ | ឧត្តរមានជ័យ | ១ | | ២.៨៣២ | ០ | ១៨.៣៩១ | ១៥.៦០០ |
| ២២ | តាកែវ | ០ | ១៨ | ៥.១៨២ | ០ | ៣៥.៣៧៤ | |
| ២៣ | កំពង់ចាម | ០ | ០៨ | ៦.៧៥៨ | ០ | ៤០.៨០៨ | ៤០.៩៩៥ |
| ២៤ | ត្បូងឃ្មុំ | ០ | ០៦ | ៤.៦៤០ | ៦៦ | ២៣.៦៧៩ | |
| ២៥ | ព្រះវិហារ | ០ | ០៥ | ១.៣០៥ | ០ | ៥.៦០៧ | |
| សរុប | | ១៤២ | | ១០៦.៣៦២ | ៤.២៣៥ | ៨៣៩.៦៩៩ | ៧១៣.១៤៥ |

• **ការងារនីតិកម្មនិងវិវាទ៖** ច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ត្រូវបាន **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានឡាយព្រះហស្តលេខាដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ និងកំពុងរៀបចំបោះពុម្ពផ្សព្វផ្សាយជាសាធារណៈឲ្យបានទូលំទូលាយ និងបន្តរៀបចំអត្ថបទក្រោមច្បាប់តាមអាទិភាព។

• បន្តសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការរៀបចំប្រកាសអន្តរក្រសួងស្តីពីកិច្ចសម្របសម្រួលក្នុងការបង្កើតនិងការគ្រប់គ្រងសត្តឃាតដ្ឋាន។

**៣.៣ ការងារស្រាវជ្រាវ៖**

• **ការងារស្រាវជ្រាវបសុព្យាបាល៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាន និងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី មេរោគជ្រូកត្រចៀកខៀវជាដើម។ ជាក់ស្តែងក្នុងខែកុម្ភៈ ឆ្នាំ២០១៦នេះ វិទ្យាស្ថានបានពិនិត្យវត្ថុវិភាគសរុបចំនួន១.៤៧៩វត្ថុវិភាគ។

• **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោ-ក្របីភ្នំតាម៉ៅមានគោសរុបចំនួន ១៦១ក្បាល ក្នុងនោះគោបាពាក្បាល គោប្រាម៉ាន់កាត់៣៣ក្បាល គោជំទង់៣៤ក្បាល គោបៅដោះ៤៨ក្បាល គោកំផែង សែន៤៣ក្បាល។ ដោយឡែកនៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប២៥៣ក្បាល ក្នុងនោះជ្រូកបាចំនួន ៨ក្បាល ជ្រូកមេ៥៣ក្បាល កូនជ្រូក៩៧ក្បាល មេជ្រូកត្រៀមលក់ចំនួន១៥ក្បាល កូនជ្រូកលក់៥០ក្បាល កូនជ្រូកងាប់ ចំនួន១៤ក្បាល និងជ្រូកថែមថ្មីចំនួន២០ក្បាល។ ការបង្កាត់ពូជតាមបែបសិប្បនិម្មិតនិងធម្មជាតិប្រព្រឹត្តទៅជាប្រក្រតី និង បានផ្សព្វផ្សាយបច្ចេកទេសបន្តទៅដល់កសិករ។

**៣.៤ ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចងក្រងឯកសារការងារផលិតកម្មនិងបសុព្យាបាលសម្រាប់ចុះក្នុង ទស្សនាវដ្តី រៀបចំកម្មវិធីផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាពិសេសផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ ដឹងពីជំងឺផ្តាសាយបក្សី ជំងឺជ្រូកត្រចៀកខៀវ និងជំងឺផ្សេងៗទៀតដែលអាចកើតឡើងជាយថាហេតុ។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការងារព្រៃឈើ

- ធ្វើការកែសម្រួលគម្រោងសំណើសុំថវិកាបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ឆ្នាំ២០១៦ នៅក្នុង ខណ្ឌរដ្ឋបាលព្រៃឈើចំនួន៤គឺ ខណ្ឌរដ្ឋបាលព្រៃឈើពោធិ៍សាត់ ខណ្ឌរដ្ឋបាលព្រៃឈើកំពត ខណ្ឌរដ្ឋបាលព្រៃឈើ មណ្ឌលគិរី និងខណ្ឌរដ្ឋបាលព្រៃឈើព្រៃវែង

- កំពុងរៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន០១កន្លែង លើផ្ទៃដី ៦១១,៦៦ហិកតា នៅក្នុងខេត្តស្ទឹងត្រែង

- កំពុងរៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន៩កន្លែង គ្របដណ្តប់ លើផ្ទៃដីទំហំសរុប១.៥១១ហិកតា៧៦៨ ក្នុងនោះខេត្តសៀមរាបចំនួន៨កន្លែងដែលមានផ្ទៃដីទំហំ១.០៧៩ហិកតា និងខេត្ត រតនគិរីចំនួន១កន្លែងដែលមានផ្ទៃដីទំហំ៤៣២ហិកតា៧៦៨

- សម្របសម្រួលនិងរៀបចំកិច្ចប្រជុំលើកទី៣ ប្រចាំឆ្នាំ២០១៥ របស់គណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ ព្រៃឈើជាតិដែលគាំទ្រពីអង្គការដៃគូរួមមាន JICA, NTFP-EP, RECOFTC, NGO Forum, MB, DPA, Harvest, WCS, SCW, ADB, UNDP Winrock WWF ដែលមានអ្នកចូលរួមចំនួន១៣៩នាក់ ក្នុងនោះស្ត្រីចំនួន១៣នាក់។

### ៤.២ ការងារអភិរក្សសត្វព្រៃ

- បានបញ្ជូនសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃសៀមប៉ាង ទៅទីស្តីការគណៈរដ្ឋមន្ត្រី

- រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វ ព្រៃព្រះរការ ដែលមានផ្ទៃដីទំហំ៩២.១៣២ហិកតា ស្ថិតនៅក្នុងខេត្តព្រះវិហារ

- តំបន់អភិរក្សសត្វក្រៀលអាងត្រពាំងថ្ម តំបន់អភិរក្សសត្វខ្សឹបកំពង់ធំ-សៀមរាប និងតំបន់ព្រៃការពារព្រះវិហារ បានទទួលភ្ញៀវទេសចរណ៍បរទេសមកទស្សនាចំនួន១២៨នាក់

- ធ្វើការអង្កេតកត់ត្រាសត្វស្លាបប្រចាំខែនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤ (អាងត្រពាំងថ្ម បឹងព្រែក ល្ពៅ អន្លង់ព្រីង និងកំពង់ធំ-សៀមរាប) ដោយបានរកឃើញសត្វស្លាបចំនួន២០៦ប្រភេទ ប្រហែល៧០.៦៣១ក្បាល

- ចុះប្រមូលទិន្នន័យ ប្រមូលសំណាកជំងឺសត្វកណ្តុរដែលស្ថិតនៅភូមិអូរចារ ឃុំស្រែព្រះ ស្រុកកែវសីមា ខេត្ត មណ្ឌលគិរី ជាលទ្ធផលប្រមូលបានសំណាកសរុបចំនួន៩៤សំណាក ពីសត្វកណ្តុរចំនួន៦ក្បាល

- ចុះប្រមូលសំណាកសត្វប្រចៀវរស់ចំនួន២១១ក្បាល ក្នុងនោះមានសត្វជ្រើងចំនួន២៣ក្បាល ដែលស្មើនឹង ៦៣៣សំណាក ដើម្បីធ្វើការពិនិត្យទៅលើការបន្តពូជ ការយកឈាម លាមក ទឹកមាត់ ទឹកនោម វាស់ប្រវែងស្លាប និង វិភាគរកមេរោគ។ ម្យ៉ាងវិញទៀតក្រុមការងារបានធ្វើជំរឿនសត្វជ្រើងនៅស្រុកកោះធំ ខេត្តកណ្តាល ដោយរាប់ឃើញ ប្រហែល៥.៣៣៣ក្បាល

- ផ្តល់ចំណីឲ្យសត្វត្មាតនៅព្រៃការពារមណ្ឌលគិរី និងតំបន់ព្រៃការពារព្រះវិហារ ដោយរាប់ឃើញត្មាតសរុបចំនួន ៨៥ក្បាល

- ធ្វើការការពារសម្បុកសត្វត្រដក់តូចចំនួន៧សម្បុក សត្វត្មាតចំនួន៣សម្បុក រំពេទន្លេចំនួន៨សម្បុក ត្រយ៉ង ចង្កំកសចំនួន២៤សម្បុក នៅខេត្តស្ទឹងត្រែង ក្រចេះ និងព្រៃការពារព្រះវិហារ។ ការពារសំបុកសត្វដើម្បីធានាសុវត្ថិភាព ពងកូន ពីព្រោះសម្បុកសត្វទាំងនេះងាយរងគ្រោះដោយសារការប្រមូលរបស់មនុស្ស និងការបំផ្លាញរបស់សត្វព្រៃ ហើយ ប្រភេទសត្វទាំងនេះជាប្រភេទជិតផុតពូជ ព្រមទាំងចុះអន្តរាគមន៍ជួយដល់ប្រជាពលរដ្ឋដែលទទួលរងការបំផ្លិចបំផ្លាញ ដោយសត្វដំរីលើផលដំណាំចំនួន៣ករណី ដែលមាន៩គ្រួសារ ទទួលរងការខូចខាតផលដំណាំមួយចំនួនរួមមាន ចេកចំនួន ៨៥ដើម ស្វាយចំនួន៣២ដើម និងខ្នុរចំនួន៥២ដើម។

### ៤.៣ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- សម្រាប់ខែកុម្ភៈ ឆ្នាំ២០១៦នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុង ចិញ្ចឹម និងថែរក្សាគឺ៖ សង្គ្រោះសត្វព្រៃថ្មីគ្រប់ប្រភេទចំនួន១៣៥ក្បាល សត្វកើតថ្មីចំនួន៧ក្បាល ដោះលែងទៅព្រៃ ធម្មជាតិវិញចំនួន៥២ក្បាល សត្វស្លាប់ចំនួន១៩ក្បាល ព្យាបាលសត្វចំនួន១២៧ក្បាល យកសំណាកទៅពិសោធន៍ចំនួន ២៦ក្បាល ធ្វើឲ្យសន្លប់ចំនួន១៣ក្បាល បញ្ចុះសត្វល្អិតចំនួន១០ក្បាល វះកាត់សាកសពសត្វចំនួន៦ក្បាល ចាក់វ៉ាក់សាំង ចំនួន២២ក្បាល សាងសង់ទ្រុងសត្វថ្មីចំនួន១.០២០ម$^{២}$ ជួសជុលផ្លូវចំនួន១២.៤០០ម$^{២}$ កាប់ឆ្ការអនាម័យព្រៃចំនួន ២.៥៧០ម$^{២}$ និងអប់រំផ្សព្វផ្សាយសិស្ស និស្សិតចំនួន៧៦នាក់

- ក្រុមហ៊ុនចំនួន៦ គ្រប់គ្រងកសិដ្ឋានចំនួន៧ កំពុងចិញ្ចឹមស្វាក្តាមចំនួន៥៥.៦៧៨ក្បាល និងនាំចេញកូនស្វាក្តាម ជំទង់ចំនួន១.១៦៥ក្បាល។

### ៤.៤ ការងារដាំដើមឈើ

- ស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអូរបឹងរូង ខេត្តកំពង់ធំ បានធ្វើការឈូសឆាយដីទំហំ១២ហិកតា

- ស្ថានីយផ្សព្វផ្សាយ និងស្តារទីជម្រាលក្បាលឆាយខេត្តព្រះសីហនុ បានធ្វើការឈូសឆាយដីទំហំ៤០ហិកតា

- បណ្តុះកូនឈើគ្រប់ប្រភេទបានចំនួន៣០.៨៨១ដើម និងចែកជូនប្រជាពលរដ្ឋដាំបានចំនួន១៦.០៨៣ដើម

- ក្រុមហ៊ុន ស៊ីងបាយអូចេក ជាដៃគូសហការដាំឈើជាមួយរដ្ឋបាលព្រៃឈើនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃ ឈើបឹងចារ បានធ្វើការឈូសឆាយដីដាំឈើចំនួន២៥០ហិកតា

- លោកស្រី Madaline មកពីសាកលវិទ្យាល័យ SUNSHINE COAST នៃប្រទេសអូស្ត្រាលី មកធ្វើការបណ្តុះ បណ្តាលស្តីពីការវិភាគនិងការកំណត់អត្តសញ្ញាណ និងវិធីសាស្ត្រប្រមូលប្រភេទសត្វល្អិតផ្សេងៗដែលមានវត្តមាននៅក្នុង ចម្ការប្រេងខ្យល់ និងការដុះតាមផ្លូវជាតិសំខាន់ៗ និងដំឡើងម៉ាស៊ីន Microscope ដែលអាចថតសត្វល្អិតជាមួយក្រុម ការងាររបស់នាយកដ្ឋានអភិវឌ្ឍចម្ការព្រៃដាំ និងព្រៃឯកជន។ ក្រៅពីការបណ្តុះបណ្តាលនៅក្នុងនាយកដ្ឋាន ក្រុមការងារក៏ បានចុះអនុវត្តផ្ទាល់ក្នុងការប្រមូលផលសំណាកសត្វល្អិត L.invasa និងសត្វល្អិតផ្សេងៗដែលមានវត្តមាននៅលើដើម ប្រេងខ្យល់នៅតាមផ្លូវជាតិលេខ១ ពីភ្នំពេញទៅខេត្តស្វាយរៀង។ ជាលទ្ធផល ក្រុមការងារបានប្រមូលសំណាកសត្វល្អិត L.invasa ចំនួន១៩សំណាក(ពងនិងសត្វល្អិតដង្កូវនៅលើស្លឹក)។

### ៤.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- កំពុងអនុវត្តគម្រោងគាំទ្រដល់កម្មវិធីព្រៃឈើជាតិជាមួយដៃគូអភិវឌ្ឍន៍ចំនួន២៥ លើគម្រោងចំនួន៥១គម្រោង ជាមួយអង្គការមិនមែនរដ្ឋាភិបាលចំនួន១៦ លើគម្រោងចំនួន៤៣គម្រោង និងគម្រោងរបស់រាជរដ្ឋាភិបាលចំនួន៩គម្រោង

- ចូលរួមកិច្ចប្រជុំក្នុងប្រទេសចំនួន៣លើក និងចូលរួមប្រជុំក្រៅប្រទេសចំនួន១លើក

- ផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តជូនក្រុមហ៊ុន និងអតិថិជនសរុបចំនួន១០គ្រឿង

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ ជូនក្រុមហ៊ុនចំនួន២ និងអតិថិជន៤នាក់ ដែលមានឈើ ហ៊ុបមូលចំនួន១.២៧៨ម$^{៣}$ កូនឈើចំនួន៥.៥៣៧ដើម អុសចម្រុះចំនួន៧.០៥០ស្ទែរ និងជ័រទឹកចំនួន២៦៥តោន

- ផ្ដល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញផលិតផលរានទេវតាចំនួន១ក្រុមហ៊ុន ដែលមានរានទេវតាចំនួន១.៥៥០គ្រឿង ស្មើនឹងចំនួន៥៦ម³

- ផ្ដល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលឈើចំនួន១ក្រុមហ៊ុន ដែលមានបរិមាណសរុប៤៨ម³

- ចុះពិនិត្យការស្នើសុំបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើជូនក្រុមហ៊ុនចំនួន២ និងបន្តសុពលភាពចំនួន២ក្រុមហ៊ុន

- រៀបចំសំណើសុំបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើជូនក្រុមហ៊ុនចំនួន៤

- ផ្ដល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចូលចំនួន២ក្រុមហ៊ុន ដែលមានបរិមាណចំនួន៨១ម³។

### ៤.៦ ការងារចំណូលព្រៃឈើ

- សម្រាប់ខែកុម្ភៈ ឆ្នាំ២០១៦នេះ ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើសរុបចំនួន៥.៦៦៧.៩៩៤.២៤០ រៀល និងចំណូលពីសេវាសាធារណៈចំនួន៤០២.០១៣.០១៨រៀល និង៤២.៤៧៦,១៥ដុល្លារ។

### ៤.៧ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ខែកុម្ភៈ ឆ្នាំ២០១៦នេះ មានសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃ នៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន១៤៤ករណី ដោយបញ្ជូនទៅតុលាការចំនួន១០៣ករណី និងពិន័យអន្តរការណ៍ចំនួន៤១ករណី

- ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន៣៥១ម³ ឈើអារចំនួន២៣០ម³ ឈើក្រាក់គ្រញូងចំនួន១ម³ និង៥០១គ.ក្រ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន៥ក្បាលនិង៣៥៣គ.ក្រ អនុផលព្រៃឈើព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត និងដីព្រៃឈើដែលកាប់រានចំនួន១៥៣ហិកតា ព្រមទាំងបានបញ្ជូនសំណុំរឿងទៅតុលាការតាមនីតិវិធី និងដកហូតរណារយន្តចំនួន៣០គ្រឿង

- បន្តដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ (Case Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប

- ស្រង់ព័ត៌មានពាក់ព័ន្ធវិស័យព្រៃឈើដែលបានចុះផ្សាយក្នុងសារព័ត៌មាននានាសរុបចំនួន៤៧ករណី ដែលការចុះផ្សាយនេះឆ្លុះបញ្ចាំងពីចំណុចវិជ្ជមានផង និងអវិជ្ជមានផងដែរ និងបានធ្វើជូនខណ្ឌរដ្ឋបាលព្រៃឈើធ្វើការបំភ្លឺមានចំនួន១៨ករណី

- សហការអនុវត្តសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ០៩ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ ស្ដីពីការបង្កើតគណៈកម្មការជាតិដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ។ ដោយឡែក ក្រុមការងារទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើនៃអធិការដ្ឋានរដ្ឋបាលព្រៃឈើទាំង៤បានខិតខំចុះល្បាត រុករកបទល្មើសព្រៃឈើនៅតាមខេត្ត-រាជធានីយ៉ាងសកម្ម ក្រោមកិច្ចសហការជាមួយកងកម្លាំងប្រដាប់អាវុធតាមបណ្ដាខេត្តនីមួយៗ។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីធ្វើអាជីវកម្ម អនុវត្តបានចំនួន១.០៥០តោន ស្មើនឹង៨,៧៥% នៃផែនការ១២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន២៣៥តោន

- នេសាទគ្រួសារក្នុងដែននេសាទ អនុវត្តបានចំនួន២៥.០០០តោន សរុបរយៈពេល២ខែបានចំនួន៤៨.០០០តោន ស្មើនឹង១៣,៩៥% នៃផែនការ៣៤៤.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន១២.២៥០តោន

- នេសាទគ្រួសារតាមវាលស្រែ អនុវត្តបានចំនួន៦.០០០តោន សរុបរយៈពេល២ខែបានចំនួន១៤.០០០តោន ស្មើនឹង៩,៧២% នៃផែនការ១៤៤.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន៤.១៥៥តោន

#### ៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន៨.៣៥០តោន សរុបរយៈពេល២ខែបានចំនួន១៤.៨៥០តោន ស្មើនឹង១៣,៥០% នៃផែនការ

១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន១.៦១៥តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គា អនុវត្តបានចំនួន៨.៧៥០តោន សរុបរយៈពេល២ខែបានចំនួន១៧.២៥០តោន ស្មើនឹង ៩,៩៨% នៃផែនការ១៧២.៨០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន៧២០តោន

- ការចិញ្ចឹមក្រពើ អនុវត្តបានចំនួន៨.១៥០ក្បាល សរុបរយៈពេល២ខែបានចំនួន១៦.៣៥០ក្បាល ស្មើនឹង ៦,៥៤% នៃផែនការ២៥០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន៦៥០ក្បាល

- ការភ្ញាស់កូនត្រីពូជ អនុវត្តបានចំនួនប្រមាណ១២.០០០.០០០កូន សរុបរយៈពេល២ខែបានចំនួន ២២.០០០.០០០កូន ស្មើនឹង១២,២២% នៃផែនការ១៨០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួនប្រមាណ៣.០០០.០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទ អនុវត្តបានចំនួន៦.១៥០តោន សរុបរយៈពេល២ខែបានចំនួន១១.៦៥០ តោន ស្មើនឹង១៤,២១% នៃផែនការ៨២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន៨៥០តោន

- ផលនេសាទសមុទ្រ អនុវត្តបានចំនួន៨៥០តោន សរុបរយៈពេល២ខែបានចំនួន១.៦០០តោន ស្មើនឹង២០% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន១០០តោន

- ការផលិតទឹកត្រី អនុវត្តបានចំនួន៤.៥០០.០០០លីត្រ សរុបរយៈពេល២ខែបានចំនួន៧.០០០.០០០លីត្រ ស្មើនឹង១៤% នៃផែនការ៥០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន១.០០០.០០០ លីត្រ។

### ៥.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ អនុវត្តបានចំនួន៨៣០តោន សរុបរយៈពេល២ខែបានចំនួន១.៧៣០តោន ស្មើនឹង ១១,៥៣% នៃផែនការ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន១២០តោន

- ផលនេសាទកែច្នៃ អនុវត្តបានចំនួន៦២០តោន សរុបរយៈពេល២ខែបានចំនួន១.០២០តោន ស្មើនឹង២០,៤០% នៃផែនការ៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន១៣០តោន។

### ៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

- សម្រាប់ខែកុម្ភៈ ឆ្នាំ២០១៦នេះ សំណុំរឿងបទល្មើសជលផលមានចំនួន២៥៥ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន២៥២ករណី និងសមុទ្រចំនួន៣ករណី

- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង៧៧.៣៨១ម៉ែត្រ លូស្បៃមុងនិងសាច់អួនចំនួន៩.៦៨៣មាត់ បង្គោល/ចម្រឹងចំនួន៤២.១២៤ដើម ឧបករណ៍ឆក់ត្រីចំនួន២៣គ្រឿង សម្រាស់ចំនួន៣១.៤១៥ម៉ែត្រក្រឡា និងលែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន៧.៤៧៩គ.ក្រ

- បានផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធចំនួន១០វគ្គ ដោយមានអ្នកចូលរួមចំនួន៥៦០នាក់ ក្នុងនោះស្ត្រីចំនួន១៣៥នាក់

- ថ្នាក់ដឹកនាំក្រសួងរួមទាំងសមត្ថកិច្ចជំនាញកំពុងបន្តជំរុញការចុះត្រួតពិនិត្យ និងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព និងការចាត់វិធានការទប់ស្កាត់និង បង្ក្រាបបទល្មើសជលផលក្រោមកិច្ចសហការយ៉ាងល្អប្រសើរជាមួយគណៈបញ្ជាការឯកភាពខេត្ត។

### ៥.៦ ការប្រមូលថវិកា

- ចំណូលពីវិស័យជលផល សម្រាប់ខែកុម្ភៈ ឆ្នាំ២០១៦ ចំនួន១២៩.១៨០.០០០រៀល សរុបបានចំនួន ២៣៩.៧៧០.០០០រៀល ស្មើ៧,៩៩% នៃផែនការ៣.០០០.០០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន១០១.៤៧៣.៥០០រៀល។

## ៦ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចុះធ្វើការដាំដុះដំណាំសណ្តែកដី និងត្រួតពិនិត្យពិសោធន៍ស្រែបង្ហាញ ប្រមូលទិន្នន័យពិសោធន៍ការងារប្រមូលផលដំឡូងមី នៅខេត្តតាកែវ កំពង់ស្ពឺ បាត់ដំបង និងខេត្តស្វាយរៀង

- ចុះធ្វើការពិសោធន៍ដោយបំបែកស្រទាប់បាតនង្គ័លដោយត្រាក់ទ័រ និងដាំដុះគ្រាប់ពូជដោយម៉ាស៊ីននៅខេត្តតាកែវ

- ចុះប្រមូលព័ត៌មានគ្រឿងយន្តកសិកម្មនៅខេត្តព្រៃវែង

- ចុះសិក្សានិងវាយតម្លៃការធ្វើស្រែបង្ហាញរបស់គម្រោង ពិនិត្យ វាយតម្លៃពិសោធន៍សណ្តែកបាយ និងពោតដំណើប នៅខេត្តតាកែវ ខេត្តកំពង់ស្ពឺ និងខេត្តកំពត

- ចុះសម្ភាសន៍កសិករស្តីពីសុវត្ថិភាពអាហារ និងត្រួតពិនិត្យស្ថានភាពដាំដុះដំណាំនៅខេត្តកណ្តាល និងខេត្តកំពត។

## ៧ ផ្នែកនីតិកម្មកសិកម្ម

### ៧.១ ការងារអាជីវកម្មសម្ភារកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្មបានចំនួន០៥ក្រុមហ៊ុន សរុបចំនួន១០១មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្មចំនួន១២ក្រុមហ៊ុន ត្រូវជា១៤ករណី
- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្មចំនួន០៣ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន០២ក្រុមហ៊ុន។

### ៧.២ ការងារមន្ទីរពិសោធន៍

- ធ្វើវិភាគសារធាតុលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំចុះបញ្ជិកាចំនួន៨ក្រុមហ៊ុន សរុបចំនួន៣៤សំណាក។

### ៧.៣ ការងារបណ្តុះបណ្តាល អប់រំ និងលើកកម្ពស់ការយល់ដឹង

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពី បទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មសម្ភារកសិកម្ម ជូនដល់មន្ទីរកសិកម្មខេត្តមណ្ឌលគិរី ខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ

- ធ្វើការបែងចែកសៀវភៅកម្រងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មចំនួន៥៥ក្បាល

- កំពុងរៀបចំសេចក្តីព្រាងប្រកាសស្តីពីគោលការណ៍ណែនាំសម្រាប់ស្លាកសញ្ញាព័ត៌មាន និងគំរូស្លាកសញ្ញាព័ត៌មាននៃថ្នាំកសិកម្ម ។

### ៧.៤ ការងារអនុវត្តច្បាប់

- ចាត់តាំងក្រុមការងារចុះត្រួតពិនិត្យការនាំចូលរបស់ក្រុមហ៊ុនដែលបានប្រកាសប្រតិវេទន៍អំពីការនាំចូល និងស្នើសុំចុះបញ្ជិកាឃ្លាំងសន្និធិជីកសិកម្ម និងថ្នាំកសិកម្ម ព្រមទាំងចុះធ្វើអធិការកិច្ចសកម្មភាពធ្វើពាណិជ្ជកម្មសម្ភារកសិកម្ម និងសកម្មភាពដឹកជញ្ជូនសម្ភារកសិកម្មល្មើសច្បាប់តាមបណ្តាច្រករបៀង រវាងព្រំដែនថៃ និងកម្ពុជា ដូចជាខេត្តពោធិ៍សាត់ និងខេត្តឧត្តរមានជ័យ

- ពិន័យអន្តរការណ៍ជាប្រាក់ចំពោះក្រុមហ៊ុន ជា ឆាយត្រឌីង ក្រុមហ៊ុន នី លីដា ខូអិលឌីធី ដេប៉ូ ប្រាក់ គីមហួន ដេប៉ូ ស៊ិម អួន និងដេប៉ូ កែវ វិសិទ្ធ។

## ៨ ផ្នែករដ្ឋបាល

- ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា ក្នុងខែចំនួន៣៩៨ច្បាប់ សរុបរយៈពេល២ខែចំនួន៦៧៨ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទ ក្នុងខែចំនួន២៤៨ច្បាប់ សរុបរយៈពេល២ខែចំនួន៦១៧ច្បាប់ និងទទួលពីរាជធានី ខេត្ត ក្នុងខែចំនួន១៣៣ច្បាប់ សរុបរយៈពេល២ខែចំនួន២១២ច្បាប់ និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល

- បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត ក្នុងខែចំនួន៧៤៨ច្បាប់ សរុបរយៈពេល២ខែចំនួន១.៣៦៦ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរ ក្នុងខែចំនួន៩៣ច្បាប់ សរុប

រយៈពេល២ខែចំនួន១៩៩ច្បាប់ ចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទ ក្នុងខែចំនួន៥០ច្បាប់ សរុបរយៈពេល ២ខែចំនួន៨៥ច្បាប់ និងផ្តល់ទិដ្ឋាការបេសកកម្មមន្ត្រីមន្ទីរកសិកម្មរាជធានី ខេត្តចំនួន៦៤ច្បាប់ សរុបមនុស្ស៩០នាក់

- ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិ។ល។

## ៩ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៥៥៩នាក់ នារីចំនួន១.៣៨៣នាក់ ស្មើនឹង២១%រួមមានៈ
  + អង្គភាពថ្នាក់កណ្តាលចំនួន៤.០២០នាក់ ក្នុងនោះនារីចំនួន៨១៣នាក់ ស្មើនឹង២០%
  + អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៥៣៩នាក់ ក្នុងនោះនារីចំនួន៥៧០នាក់ ស្មើនឹង២២%
- ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន៨នាក់ ក្នុងនោះសុំលាឈប់ពីការងារចំនួន២នាក់ និងមរណភាពចំនួន៦នាក់
- ចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកពីការងារចំនួន០៥នាក់ ក្នុងនោះឈប់សម្រាកប្រចាំឆ្នាំចំនួន៣នាក់ និងសុំច្បាប់ព្យាបាលជំងឺចំនួន២នាក់
- ប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន០១នាក់ ផ្ទេរចូលក្នុងក្រសួងចំនួន០១នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន០២នាក់
- ប្រកាសព្យួរការងារមន្ត្រីរាជការចំនួន២០នាក់
- បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួងទៅចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន២៣នាក់ និងក្នុងប្រទេសចំនួន២២នាក់
- ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ១០ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានចាត់បញ្ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការក្រោមឱវាទទៅចូលរួមកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា និងទស្សនកិច្ចសិក្សាសរុបចំនួន៤១រូប នៅប្រទេសចំនួន១៤
- អន្តរាគមន៍ទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម និងកសិ-ពាណិជ្ជកម្ម រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋហ្វីលីពីន
- រៀបចំលិខិតជូន IPPC Secretariat Viale delle Terme di Caracalla, Room, Italy ករណី Request for Financial Support for Cambodian Participant to attend the Eleventh Session of the Commission on Phytosanitary Measures, 4th -8 th April 2016 in Rome, Italy
- ស្នើសុំផ្តល់ទិដ្ឋាការជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាល នៅប្រទេសជប៉ុន(០១រូប) និងប្រទេសអូស្ត្រាលី(០១រូប)។

## ១១ ការងារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១១.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៥-២០១៦ សរុបចំនួន៩៩៤នាក់ (ស្ត្រី៣៥០នាក់) ក្នុងនោះនិស្សិតថ្នាក់បរិញ្ញាចំនួន៧៥១នាក់(ស្ត្រី២៨២នាក់) និងនិស្សិតថ្នាក់បរិញ្ញារងចំនួន២៤៣នាក់(ស្ត្រី៦៨នាក់)។ សាលាបានទទួលនិស្សិតថ្នាក់វិទ្យាសាស្ត្រមូលដ្ឋាននិងបរិស្ថាន(ថ្នាក់បរិញ្ញាបត្ររងអាហារូបករណ៍) ឲ្យចូលរៀនសម្រាប់ឆ្នាំសិក្សា២០១៥-២០១៦។ ពិនិត្យកែតម្រូវលើ Proposal របស់និស្សិតថ្នាក់បរិញ្ញាបត្រឆ្នាំទី៤ គ្រប់ជំនាញ និងបញ្ជូននិស្សិតចុះកម្មសិក្សាសម្រាប់សរសេរសារណាបញ្ចប់ការសិក្សា និងបន្តរៀបចំពិសោធន៍ដំណាំស្រូវជប៉ុន (Japonica seeds) ព្រមទាំងពូជបន្លែ

ពីជប៉ុន និងបញ្ជូននិស្សិតចំនួន២នាក់ទៅធ្វើកម្មសិក្សានៅប្រទេសជប៉ុន។ សាលាបាននិងកំពុងសាងសង់រោងពិសោធន៍ចំនួន៣ សម្រាប់ការដាំដំណាំ និងបន្លែពិសោធន៍នៅក្នុងបរិវេណសាលាជាតិកសិកម្មព្រែកលៀប ព្រមទាំងបន្តសហការជាមួយគ្រូហ្វីលីពីនដើម្បីជំរុញការបង្រៀនភាសាអង់គ្លេសទៅតាមកម្រិត។

### ១១.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៥-២០១៦ សរុបមានចំនួន៩០៨នាក់(ស្ត្រី៣៧០នាក់) រួមមាន៖

- និស្សិតអាហារូបករណ៍សរុប៨៥៩នាក់ (ស្ត្រី៣៥៤នាក់) ក្នុងនោះថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មចំនួន៤៥៥នាក់(ស្ត្រី១៧៨នាក់) និងថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសកសិកម្មចំនួន១២៥នាក់(ស្ត្រី៥១នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ
- និស្សិតសិក្សាបង់ថ្លៃចំនួន៤៩នាក់ (ស្ត្រី១៦នាក់) ថ្នាក់បរិញ្ញាបត្រចំនួន៣៨នាក់(ស្ត្រី១៥នាក់) និងថ្នាក់បរិញ្ញាបត្ររងចំនួន១១នាក់ (ស្ត្រី១នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

បញ្ជូននិស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មឆ្នាំទី៤ និងនិស្សិតថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសកសិកម្មឆ្នាំទី២ ទាំង៥ជំនាញឲ្យចុះទំនាក់ទំនងធ្វើកម្មសិក្សា ចងក្រងសារណាបទបញ្ចប់ការសិក្សានៅតាមមូលដ្ឋាន តាមមន្ទីរ ស្ថាប័នរដ្ឋ និងតាមបណ្តាអង្គការនានា ព្រមទាំងចុះធ្វើការពិសោធន៍ស្រាវជ្រាវលើទីវាលតាមមុខជំនាញនីមួយៗផងដែរ។ បានទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍នានាដើម្បីកៀរគររកជំនួយ ក្នុងនោះកំពុងសហការ ជាមួយអង្គការពេទ្យសត្វគ្មានព្រំដែនដើម្បីរៀបចំមន្ទីរពិសោធន៍សត្វ និងបណ្តុះបណ្តាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍ និងសហការជាមួយអង្គការ OISCA បញ្ជូននិស្សិតចុះជួយអប់រំសិស្សសាលាបឋមសិក្សានិងវិទ្យាល័យ នៅស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ អំពីបរិស្ថាន និងដាំដើមឈើតាមសាលារៀន។ បញ្ជូននិស្សិតជំនាញក្សេត្រសាស្ត្រចំនួន២រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលរយៈពេល១ឆ្នាំ នៅប្រទេសជប៉ុន។ ទំនាក់ទំនងជាមួយអង្គការ KOICA ដើម្បីផ្តល់អាហារូបករណ៍សម្រាប់មន្ត្រីទៅបន្តការសិក្សាថ្នាក់អនុបណ្ឌិតនៅប្រទេសកូរ៉េ។ សហការជាមួយសាកលវិទ្យាល័យ SHIN JU ប្រទេសជប៉ុនក្នុងការផ្តល់ពូជដង្កូវនាងព្រៃ ជួយបណ្តុះបណ្តាលនិងរៀបចំមន្ទីរពិសោធន៍បាណកសត្វ និងសហការជាមួយ DTRA (Defence Threat Reduction Agency) ដើម្បីបើកវគ្គអំពីអេពីឌេមីសាស្ត្រសត្វដល់និស្សិត និងមន្ត្រីជំនាញ។

### ១១.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៥ សរុបមានចំនួន៣.៩២៤នាក់(ស្ត្រី១.១៨៧នាក់) ចែកចេញជា១០មហាវិទ្យាល័យ គឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញារង ថ្នាក់បរិញ្ញាវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តម ដើម្បីបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ សាកលវិទ្យាល័យបានប្រឡងបញ្ចប់កម្មវិធីសិក្សាឆមាសទី១ហើយមាននិស្សិតមួយចំនួនបានចាប់ផ្តើមចុះធ្វើកម្មសិក្សារបស់ខ្លួននៅតាមមូលដ្ឋានផលិតកម្មជាក់ស្តែង។ ក្រោមជំនួយរបស់ USAID សាកលវិទ្យាល័យបានចាប់ផ្តើមអនុវត្តន៍គម្រោងថ្មី ស្តីពីការបង្កើតឧបករណ៍កសិកម្មធុនតូចសមស្របសម្រាប់កសិករកម្ពុជា ដោយសហការជាមួយសាកលវិទ្យាល័យ North Carolina Agricultural and Technical State University និង University of Illinois និងបានរៀបចំធ្វើគម្រោងថ្មីមួយទៀតដើម្បីបង្កើត Center for Excellence on Sustainable Agriculture and Nutrition នៅក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដោយសហការជាមួយសាកលវិទ្យាល័យ Kansas State University នៅសហរដ្ឋអាមេរិក។ ដោយឡែក សាកលវិទ្យាល័យបានទទួលនិស្សិតបរទេសមកធ្វើកម្មសិក្សាចំនួន១៤នាក់ ក្នុងនោះមកពីសាកលវិទ្យាល័យ Kon Kuk ប្រទេសកូរ៉េ ជំនាញបសុពេទ្យ ១០នាក់ និងមកពីសាកលវិទ្យាល័យកូឡាលំពួរ ប្រទេសម៉ាឡេស៊ីចំនួន៤នាក់ ជំនាញព័ត៌មានវិទ្យា ព្រមទាំងបានសហការជាមួយនាយកដ្ឋានឧត្តមសិក្សា និងអង្គការSEARCA បានធ្វើសិក្ខាសាលាមួយស្តីពីភាពជាអ្នកដឹកនាំក្នុងឧត្តម

សិក្សាកសិកម្មកម្ពុជា (LEAP Cambodia) ជូនដល់មន្ត្រីថ្នាក់ដឹកនាំនៃគ្រឹះស្ថានឧត្តមសិក្សានានា ដែលមានកម្មវិធីបណ្តុះបណ្តាលជំនាញកសិកម្មផងដែរ ។

គ្រឹះស្ថានឧត្តមសិក្សាកសិកម្មទាំង៣ខាងលើ តែងតែបញ្ជូននិស្សិតឱ្យចុះធ្វើកម្មសិក្សានៅតាមអង្គភាពជំនាញនៅទីវាល និងតាមបណ្តាក្រុមហ៊ុនមួយចំនួនដូចខែមុនៗដែរដើម្បីផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងក៏ដូចជាការបង្ហាត់ឱ្យចេះកែច្នៃកសិផលមួយចំនួនសម្រាប់ការធ្វើកសិពាណិជ្ជកម្ម រួមទាំងការពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូឱ្យកាន់តែទូលំទូលាយ។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ជារួម ល្បឿនការងារបង្កបង្កើនផលរដូវប្រាំងទទួលបានលទ្ធផលល្អប្រសើរ ជាពិសេសដំណាំស្រូវសម្រេចបាន ១១៧,២៨%នៃផែនការ ទិន្នផលជាមធ្យមទទួលបាន៤,៣៤២តោន/ហិកតា តិចជាងឆ្នាំមុនចំនួន៣៧គ.ក្រ/ហិកតា។ មកទល់ពេលនេះ ខេត្តចំនួន២៤បានបញ្ចប់ការងារដាំដុះស្រូវប្រាំងជាស្ថាពរហើយៗនៅសល់ខេត្តចំនួន១ទៀត(ប៉ៃលិន) នឹងត្រូវបញ្ចប់ការងារដាំដុះក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ។ ជាមួយនេះ ប្រជាកសិករបាននឹងកំពុងមមាញឹកដំណើរការច្រូតកាត់ឲ្យទាន់ពេលវេលា ដើម្បីជៀសវាងការបាត់បង់ផលស្រូវក្រោយពេលប្រមូលផល។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានវិធានការបន្តជំរុញការអប់រំ ណែនាំដល់ប្រជាកសិករឲ្យបង្កើនការខិតខំថែទាំដំណាំស្រូវប្រាំង ក៏ដូចជាការថែទាំដំណាំផ្សេងៗទៀតនៅទីកន្លែងដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ក្នុងស្មារតីសន្សំសំចៃទឹក ព្រមទាំងផ្សព្វផ្សាយឲ្យបានទូលំទូលាយបន្ថែមទៀតលើការយកចិត្តទុកដាក់ថែទាំសុខភាពសត្វ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺសត្វដែលអាចកើតឡើងជាយថាហេតុនៅក្នុងរដូវប្រាំងនេះ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗជាធរមានយ៉ាងយកចិត្តទុកដាក់ ដោយជំរុញការចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាពពិតមែនតែនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយ។ ជាពិសេស ចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ០៩ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការជាតិដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព។ ដោយឡែក អធិការដ្ឋានរដ្ឋបាលព្រៃឈើទាំង៤ក្រោមកិច្ចសហការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិទាំង២៥ខេត្ត-រាជធានី បានចុះប្រតិបត្តិការត្រួតពិនិត្យ ទបស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើព្រមៗគ្នាផងដែរ។ ទន្ទឹមនឹងនេះ ក្រសួងក៏បានរៀបចំសារាចរណែនាំបន្ថែមទៀតអំពីការការពារ ទប់ស្កាត់ភ្លើងឆេះព្រៃនៅក្នុងរដូវប្រាំងនេះ។ លើសពីនេះទៀត ផ្នែកសេវាកម្ម ដំណើរការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់តាមផ្នែកសំខាន់ផ្សេងៗ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មជី-ថ្នាំកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការឆ្នាំ ២០១៦នេះ។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ :

- តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតចង្រៃជាយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗនិងជំរុញការងារបង្កបង្កើនផលរដូវប្រាំងនេះឱ្យបានសម្រេចតាមផែនការ
- តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែន
- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយផលប៉ះពាល់បង្កដោយគ្រោះរាំងស្ងួត គ្រោះខ្វះទឹកដែលអាចកើតឡើងជាយថាហេតុ និងដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឱ្យបានច្រើនដើម្បីផ្តល់កម្រៃបន្ថែមជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ

- ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

- ជំរុញការរៀបចំសន្និបាតកសិករ និងសន្និបាតកសិកម្មទូទាំងប្រទេសនាពេលខាងមុខ និងលើកទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១៦-២០១៧

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

- បច្ចុប្បន្ននេះ ដោយមានការធ្លាក់ចុះនៃតម្លៃកៅស៊ូនៅលើទីផ្សារដែលធ្វើឲ្យម្ចាស់ច្បារពូជកៅស៊ូសម្រេចចិត្តដកចេញនូវច្បារពូជរបស់ខ្លួន ហើយកសិករមួយចំនួនទៀតបានកាប់ដើមកៅស៊ូចោលនិងដាំដំណាំផ្សេងៗជំនួសវិញ។ ក្រសួងបានជំរុញឲ្យអង្គភាពជំនាញចុះធ្វើការអប់រំផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូឲ្យបានទូលំទូលាយ ធ្វើការវិភាគសេដ្ឋកិច្ចនិងផ្តល់ក្តីសង្ឃឹមអំពីតម្លៃកៅស៊ូនៅលើទីផ្សារដែលអាចនឹងឡើងថ្លៃវិញនៅពេលអនាគត។

**២ ផ្នែកផលិតកម្មនិងបសុព្យាបាល :**

- បន្តចាត់វិធានការដោយសហការជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺជ្រូកត្រចៀកខៀវ ក៏ដូចជាជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្មរាជធានី ខេត្ត ស្រុក ដើម្បីត្រៀមនិងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀតព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឱ្យបានទូលំទូលាយ

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

- បន្តចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានការបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឱ្យបានសមស្របតាមនីតិវិធី

- ជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល

- បន្តសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការរៀបចំប្រកាសអន្តរក្រសួងស្តីពីកិច្ចសម្របសម្រួលក្នុងការបង្កើតនិងការគ្រប់គ្រងសត្តឃាតដ្ឋាន។

**៣ ផ្នែករុក្ខាព្រៃឈើ :**

- បន្តជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២ និងចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ០៩ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការជាតិ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព។

**៤ ផ្នែកជលផល** :

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល

- ពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវដកហូត និងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៦ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ** :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមបណ្តាខេត្ត រាជធានី។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម

- បន្តពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មខេត្ត រាជធានី ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- ត្រៀមរៀបចំបង្កើតការិយាល័យច្រកចេញ-ចូលតែមួយ ដើម្បីបម្រើសេវាសាធារណៈឲ្យមានតម្លាភាព

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ។ ទន្ទឹមនឹងនេះ ក៏បានគិតគូរអំពីការបញ្ចូលការងារយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់តាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្តែង

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស

- បន្តរៀបចំការធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផលតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា តាមស្មារតីនៃលិខិតលេខ១៣០៣ សជណ.សរ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

- ចូលរួមអនុវត្តអនុក្រឹត្យលេខ៣៨អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលតួនាទីនិងភារកិច្ចរបស់ក្រសួងបរិស្ថាន និងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពាក់ព័ន្ធនឹងសមត្ថកិច្ចនិងការគ្រប់គ្រងតំបន់វិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ច និងការគ្រប់គ្រងតំបន់ការពារនិងអភិរក្សព្រៃឈើនិងជលផល

- ជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត អត្ថបទក្រោមច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ស្តង់ដារ គោលការណ៍ និងហេដ្ឋារចនាសម្ព័ន្ធនៅតាមអង្គភាពក្រោមឱវាទ ដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាពីកសិកម្មបែបវិបុលវប្បកម្ម មានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្ម មានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលធាតុអាកាស និងការផលិតសម្រាប់ឈានទៅរកការធ្វើសមាហរណកម្មពាណិជ្ជកម្មផលិតផលកសិកម្មក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននិងនៅក្នុងតំបន់ផងដែរ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិនា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**